ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-រឿងក្តីលេខ ១៣២៦ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០០៩

-សញ្ញាណនៃរឿងក្តី:'ប្តឹងសុំទាមទារប្រាក់

-កាលបរិច្ឆេទបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២

-សាលក្រមលេខ: ៧៤ "ជ"

-កាលបរិច្ឆេទនៃការប្រកាសសាលក្រមថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅៈ

-ដើមចោទឈ្មោះ [redacted] ហេងហួរ ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ០៨E₁ ផ្លូវលេខ៥១៤ ក្រុម១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-ចុងចម្លើយឈ្មោះ [redacted] ណុប ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ១៩៥ ផ្លូវលេខ១០១៩ ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

### <u>អង្គហេតុ និង ចំណុចវិវាទ</u>

**ក-ការទាមទាររបស់ដើមចោទ**

ទាមទារប្រាក់ចំនួន ១១,០៩៥ $ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក)

ការប្រាក់តាមច្បាប់

សំណងជម្ងឺចិត្តចំនួន ៣,០០០ $ (បីពាន់ដុល្លាអាមេរិក)

**ខ-ការពន្យល់ត្រួសៗអំពីរឿងក្តី**

-ដើមចោទឈ្មោះ [redacted] ហេងហួរ បានធ្វើសេចក្តីថ្លែងការណ៍ថា: នាងខ្ញុំនៅតែរក្សាពាក្យបណ្តឹង ដែលប្តឹងទាមទារប្រាក់ចំនួន ១១,០៩៥ $ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លារអាមេរិក) ពីឈ្មោះ: [redacted] ណុប ដែលមិនទាន់បានសងមកនាងខ្ញុំ ។ នាងខ្ញុំនិងប្តីជាអ្នករកស៊ីធ្វើការ ម៉ៅការសំណង់ សាងសង់ផ្ទះអោយចុងចម្លើយ ។ នាងខ្ញុំជាអ្នកទិញសំភារៈផ្គត់ផ្គង់ និងជាអ្នកទទួលយកប្រាក់ ពីចុងចម្លើយ ចំណែកប្តីនាងខ្ញុំជាអ្នកឈរមើលខុសត្រូវការសាងសង់ ។ តំលៃក្នុងការម៉ៅការសំណង់ចំនួន ៣៦,០០០$ (បីម៉ឺនប្រាំមួយពាន់ដុល្លាអាមេរិក) គឺជាន់ផ្ទាល់ដី ចំនួនពីរល្វែង តំលៃ ៣០,០០០ $ (បីម៉ឺនដុល្លាអាមេរិក) និងជាន់ទី១ ចំនួនពីរល្វែង តំលៃ ៦,០០០ $ (ប្រាំមួយពាន់ដុល្លាអាមេរិក) ។ ចុងចម្លើយបានឲ្យលុយនាងខ្ញុំតែ ចំនួន ២៤,៩៩៥$ (ពីរម៉ឺនបួនពាន់ ប្រាំបួនរយកៅសិបប្រាំដុល្លាអាមេរិក) គឺនៅខ្វះចំនួន ១១,០៩៥ $ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក) ទៀតដែលមិនទាន់អោយនាងខ្ញុំ ។ ផ្ទះនេះនាងខ្ញុំ និងប្តីបានធ្វើអោយគាត់អស់ហើយ នាងខ្ញុំសូមទាមទារឲ្យចុងចម្លើយ ប្រគល់ក្ការពុម្ពដែល បានយកទៅធ្វើផ្ទះឲ្យចុងចម្លើយ និងឈើជន្ទល់ត្រលប់មកវិញ ។ ដើមចោទសុំឲ្យតុលាការបង្ហាញ ភស្តុតាងប្រសិនបើចុងចម្លើយពិតបានជាសងលុយមកនាងខ្ញុំមែន ។ ដើមចោទបានស្នើសុំឲ្យតុលាការពិនិត្យភស្តុតាង ជាឯកសារមានដូចជា:



Scanned with CamScanner

• វិក័យបត្រចំណាយក្នុងការសាងសង់មួយចំនួន
• កិច្ចសន្យាសាងសង់ផ្ទះ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩

-ចុងចម្លើយឈ្មោះ [redacted] ណុប បានធ្វើសេចក្តីថ្លែងការណ៍ថា: ចំពោះការប្តឹងសុំទាមទារប្រាក់ចំនួន ១១,០៩៥$ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក) នោះខ្ញុំបាទសូមបដិសេធទាំងស្រុងគឺខ្លួនពុំបានជំពាក់ដើមចោទទេ ។ ខ្លួនទទួលស្គាល់ថាពិតជានៅខ្វះដើមចោទចំនួន ១,០៨០$( មួយពាន់ប៉ែតសិបដុល្លាអាមេរិក) ថ្លៃក្រៅម៉ៅការចាក់ប្លង់សេខាងលើបន្ថែម ដែលជាលក្ខខណ្ឌ ដើម្បីអោយដើមចោទ និងឈ្មោះ [redacted] វី ធ្វើផ្ទះរបស់ខ្លួនអោយហើយទើបប្រគល់លុយនៅសល់ឲ្យទៅដើមចោទ ។ ចំពោះការសាងសង់ផ្ទះ ដែលមិនទាន់ហើយ ដែលជាកាតព្វកិច្ចរបស់ដើមចោទ ខ្លួនបានជួលគេសាងសង់បង្ហើយអស់ហើយ ។ ចុងចម្លើយបានស្នើសុំឲ្យតុលាការពិនិត្យភស្តុតាងជាឯកសារ និងសាក្សីមានដូចជា:

-កំណត់ហេតុស្តាប់ការបំភ្លឺរបស់កស្សិណសាក្សីឈ្មោះ [redacted] ចាន់ណា
-កំណត់ហេតុស្តាប់ការបំភ្លឺរបស់កស្សិណសាក្សីឈ្មោះ [redacted] គឹមសុខ
-កំណត់ហេតុស្តាប់ការបំភ្លឺរបស់កស្សិណសាក្សីឈ្មោះ [redacted] អឿន
-សាក្សីឈ្មោះ [redacted] ចាន់ណា
-សាក្សីឈ្មោះ [redacted] គឹមសុខ
-សាក្សីឈ្មោះ [redacted] អឿន

**គ-ចំណុចទំនាស:**

ដើមចោទប្តឹងសុំទាមទារប្រាក់ចំនួន ១១,០៩៥$ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក) ឯចុងចម្លើយបានអះអាងថាបានសងរួចរាល់ហើយ ។

**<u>សំអាងហេតុ</u>**

តាមលទ្ធផលនៃការសាកសួរភាគី និង ពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់មកឃើញថា:

១.តាមកិច្ចសន្យាសង់ផ្ទះ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ដើមចោទជាអ្នកម៉ៅការសំណង់ឲ្យចុងចម្លើយ ជាម្ចាស់ក្នុងតំលៃ USD ៣០,០០០ (បីម៉ឺនដុល្លាអាមេរិក) ។

២.ក្នុងការសាងសង់ ចុងចម្លើយ បានប្រគល់ប្រាក់អោយដើមចោទចំនួន ០៤ លើករួចហើយ ដែលមួយលើកៗគឺចំនួន USD ៥,០០០ (ប្រាំពាន់ដុល្លាអាមេរិក) សរុបទៅចំនួន USD ២០,០០០ (ពីរពាន់ដុល្លាអាមេរិក) តាមលិខិតប្រគល់ទទួលប្រាក់ ដែលមានលិខិតប្រគល់ទទួលត្រឹមត្រូវ មាននៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ ចំនួន USD ៥,០០០ (ប្រាំពាន់ដុល្លាអាមេរិក) , ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ ចំនួន USD ៥,០០០ (ប្រាំពាន់ដុល្លាអាមេរិក), ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៩ ចំនួន USD ៥,០០០ (ប្រាំពាន់ដុល្លាអាមេរិក) និងនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៩ ចំនួន USD ៥,០០០ (ប្រាំពាន់ដុល្លាអាមេរិក) ។

៣.តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ អាចអោយតុលាការជឿបានព្រោះ ប្រាក់ដែលនៅជំពាក់ខាងលើគឺចំនួន USD ១០,០០០ (មួយម៉ឺនដុល្លាអាមេរិក) ចំណែកប្រាក់ចំនួន USD ១,០៩៥ (មួយពាន់កៅសិបប្រាំដុល្លាអាមេរិក) ទៀតជាប្រាក់ដែលចុងចម្លើយសុំឲ្យ ដើមចោទចាក់ប្លង់សេបន្ថែម គឺនៅជំពាក់ ហើយចុងចម្លើយក៏ទទួលស្គាល់ថាបានចាក់ប្លង់សេខាងលើដែរ ។



Scanned with CamScanner

៤.ការដែលចុងចម្លើយ បានអះអាងថាប្រាក់ដែលដើមចោទទាមទារនោះ បានឲ្យដើមចោទអស់ តាមសេចក្តីថ្លែងការណ៍នេះ ព្រមទាំងចម្លើយរបស់សាក្សី ពុំមានភាពច្បាស់លាស់ ដែលអាចអោយតុលាការជឿបានព្រោះថាចម្លើយសាក្សី ថាបានឃើញការប្រគល់ទទួលប្រាក់ មិនថាមានចំនួនប៉ុន្មានឡើយ ហើយក្នុងដំណាក់កាលណាមួយនៃការសាងសង់ទេ ហើយបើមានការប្រគល់ទទួលប្រាក់ក៏ត្រូវធ្វើឡើងតាមលិខិតដែរ ។

៥.ដើមចោទបានទាមទារឲ្យចុងចម្លើយបង់អត្រាការប្រាក់តាមច្បាប់ តុលាការនឹងពិចារណា តាមការទាមទារតាមមាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី ។

៦.ដើមចោទទាមទារសំណងជម្ងឺចំនួន USD ៣,០០០ (បីពាន់ដុល្លាអាមេរិក)តុលាការមិនអាចសម្រេចបានឡើយព្រោះថារឿងក្តីទាមទារប្រាក់ពុំមានតម្លៃតបស្នងជាព្យសនកម្ម ចំពោះជម្ងឺចិត្តទេ ប៉ុន្តែការទាមទារប្រាក់ចំពោះការខាតបង់ពេលវេលា និងផលទុនផ្សេងៗដែលមិនបានយកប្រាក់នោះ ទៅប្រើតុលាការពិចារណាតាមភាពសមហេតុផល។

៧-ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមបញ្ញាតិមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសន្និដ្ឋាន

គប្បីពិចារណានិងសម្រេចដូចខាងក្រោមៈ

-ប្រាក់ដើមចំនួន USD ១១,០៩៥ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក)

-អត្រាការប្រាក់ ៥% ក្នុងមួយឆ្នាំនៃប្រាក់ដើមចំនួន USD ១១,០៩៥ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក) រហូតដល់ថ្ងៃសងគ្រប់ចំនួន មាត្រា ៣១៨ ក្រមរដ្ឋប្បវេណី ។

-ការខាតបង់ផ្សេងៗ

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ជាភាគីចាញ់ក្តី អនុលោមតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១-ឲ្យចុងចម្លើយឈ្មោះ[redacted] ណុប សងប្រាក់ទៅដើមចោទឈ្មោះ[redacted] ហេងហួរ ៖

ក.ប្រាក់ដើមចំនួន USD ១១,០៩៥ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក) ។

ខ.សងការប្រាក់ចំនួន ៥% ក្នុងមួយឆ្នាំ លើទឹកប្រាក់ដើមចំនួន USD ១១,០៩៥ (មួយម៉ឺនមួយពាន់កៅសិបប្រាំដុល្លាអាមេរិក) រហូតដល់ថ្ងៃសងគ្រប់ចំនួន ។

គ. សងប្រាក់ខាតបង់ផ្សេងៗចំនួន USD ៥០០ (ប្រាំពាន់ដុល្លាអាមេរិក) ។ ការទាមទារលើសពីនេះត្រូវច្រានចោល។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និង ត្រា ៖ អឿន សៀន

---

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២

ក្រឡាបញ្ជី

[redacted]